# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ព្រះពុទ្ធសាសនានៅកម្ពុជានឹងគង់វង់ដោយអនុវត្ត
## កត្តាពីរយ៉ាងគឺការអប់រំ និងរដ្ឋឧបត្ថម្ភ

**Website: www.hoksavann.org**

ថ្ងៃទី២១ កុម្ភៈ ២០១០



ជនជាតិខ្មែរគោរពព្រះពុទ្ធសាសនារាប់ពាន់ឆ្នាំមកហើយ ដោយពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាពាក្យពិតដូចពាក្យថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ជាដើម ។ ពាក្យពិតនេះអាចធ្វើឲ្យអ្នកប្រតិបត្តិតាមបានសេចក្តីសុខចំរើន ដោយលះបង់អំពើអាក្រក់ ហើយធ្វើតែអំពើល្អ ។ ដូច្នេះកូនចៅជំនាន់ក្រោយគប្បីសិក្សាអប់រំឲ្យយល់តម្លៃព្រះពុទ្ធសាសនា ហើយនាំគ្នាគោរពបន្តពីដូនតារបស់ខ្លួន ។ ការអប់រំជាការសំខាន់ណាស់ អាចកែប្រែចិត្តគំនិតចរិយាមារយាទអាក្រក់មកល្អវិញបាន បើគេអប់រំតាមផ្លូវល្អ ផ្លូវត្រូវ ដូចជាអប់រំតាមមាគ៌ារបស់ព្រះពុទ្ធសាសនា ។ យុវជននិងយុវនារីខ្មែរនៅប្រទេសកម្ពុជា ត្រូវបានទទួលសិក្សាអប់រំពីមាតាបិតាពីគ្រូបង្រៀន និងពីព្រះសង្ឃព្រះពុទ្ធសាសនា ។ ការសិក្សាអប់រំនេះ បានធ្វើឲ្យចរិតលក្ខណៈរបស់កូនចៅខ្មែរ មានផ្នត់គំនិតចរិយាមារយាទ ស្របតាមអត្តសញ្ញាណជាតិខ្លួន ។ ភាគច្រើននៃកូនចៅប្រុសៗខ្មែរបានបួសអប់រំសីលធម៌ព្រះពុទ្ធសាសនា ចំណែកកូនចៅស្រីៗត្រូវម្តាយឪពុកដែលជាពុទ្ធសាសនិកជន តែងអប់រំកូនចៅរបស់ខ្លួនឲ្យមានសីលធម៌តាមធម៌ព្រះពុទ្ធសាសនា ។ នៅតាមសាលារៀន ក៏មានបញ្ចូលកម្មវិធីព្រះពុទ្ធសាសនាផ្នែកសីលធម៌ឲ្យសិស្សសិក្សាដែរ ។ ការបញ្ចូលសីលធម៌ព្រះពុទ្ធសាសនា ដែលជាសីលធម៌ល្អបណ្តាច់នេះឲ្យសិស្សសិក្សាមានសារៈសំខាន់ណាស់ សំរាប់លើកដំកើងសីលធម៌ឲ្យខ្ពស់ឡើងវិញ ហើយទុកជាការជួយផ្លូវអាណាចក្រ ព្រោះការអប់រំយុវជន ដែលជាធនធានមនុស្សឲ្យមានចរិយាល្អនេះ គឺស្របតាមសង្គមកម្ពុជា ដែលកំពុងមានដំណើរឆ្ពោះទៅរកការលូតលាស់ចំរើន ។ មួយទៀត មាតាបិតាដែលជាពុទ្ធសាសនិកជន គប្បីបង្កើនការអប់រំសីលធម៌ព្រះពុទ្ធសាសនា ឲ្យបានខ្លាំងក្លាថែមទៀត ដែលយុវជននិងយុវនារីដែលជាកូនចៅរបស់ខ្លួន ។ ការអប់រំនេះជាការសំខាន់ចាំបាច់ មិនត្រូវធ្វេសប្រហែសថា ម្តាយឪពុកកាន់ព្រះពុទ្ធសាសនា កូនចៅក៏នៅតែកាន់ព្រះពុទ្ធសាសនាដូចនេះឡើយ ព្រោះបើម្តាយឪពុកមិនបានពន្យល់តម្លៃព្រះពុទ្ធសាសនាឲ្យកូនចៅយល់ច្បាស់លាស់ទេ កូនចៅក៏អាចដឹងបានឡើយ ។ បើម្តាយឪពុកគ្មានសមត្ថភាពពន្យល់ទេ គួរនាំកូនចៅមកវត្ត ដើម្បីឲ្យព្រះសង្ឃជួយណែនាំពន្យល់ ។ បើកូនចៅមិនបានដឹងអំពីតម្លៃព្រះពុទ្ធសាសនា ថ្ងៃណាមួយកូនចៅរបស់ខ្លួនអាចងាកចិត្តចេញពីជំនឿឪពុកម្តាយ ដោយការអូសទាញពីសាសនាដទៃ ។ ដូច្នេះការអប់រំជាការពង្រឹងស្មារតីដល់យុវជននិងយុវនារីខ្មែរ ឲ្យមានជំនឿរឹងមាំក្នុងព្រះពុទ្ធសាសនាមិនងាករេ ទោះបីសាសនាដទៃព្យាយាមអូសទាញដោយមធ្យោបាយណាក៏ដោយ ។

ក្រៅពីការអប់រំ នៅមានកត្តាមួយទៀតដែលធ្វើឲ្យព្រះពុទ្ធសាសនាខ្មែរគង់វង់ គឺការឧបត្ថម្ភពីរដ្ឋ ។ ដោយរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដូច្នេះរដ្ឋត្រូវមានកាតព្វកិច្ចឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យមានការលូតលាស់ចំរើន ដោយមធ្យោបាយផ្សេងៗ មានឧបត្ថម្ភពុទ្ធិកសិក្សា គឺការសិក្សារបស់ព្រះសង្ឃ និងបញ្ចូលព្រះពុទ្ធសាសនាក្នុងកម្មវិធីសិក្សា ក្នុងក្រសួងអប់រំគ្រប់ភូមិសិក្សាឲ្យបានច្រើនម៉ោងជាដើម ។ មួយទៀត ត្រូវធ្វើច្បាប់គ្រប់គ្រងពាហិរសាសនា គឺសាសនាដទៃកុំឲ្យដើរផ្សាយសាសនារបស់ខ្លួនមានលក្ខណៈរំលោភច្បាប់ ដូចជាបញ្ចុះបញ្ចូលយុវជននិងយុវនារីខ្មែរដែលជាវ័យក្មេងមិនទាន់ទទួលខុសត្រូវតាមផ្លូវច្បាប់ ឲ្យជឿសាសនារបស់ខ្លួនជាដើម ។ សម័យសាកលភាវូបនីយកម្ម ពុំមែនមានន័យថា អ្វីដែលចូលទៅប្រទេសកម្ពុជា ត្រូវតែជឿត្រូវតែទទួលកាន់យកនោះឡើយ ប៉ុន្តែមានន័យថា អ្វីដែលចូលទៅត្រូវលើកយកមកពិចារណា តើរបស់នោះមានប្រយោជន៍ដល់ប្រទេសកម្ពុជាឬទេ ? តើរបស់នោះស្របស្រួលទៅតាមចិត្តគំនិតខ្មែរឬទេ ? បានសេចក្តីថា របស់ដែលគួរទទួលនោះ គឺតិកនិកបច្ចេកទេសផ្សេងៗដែលខ្មែរមិនទាន់មាន ឬមានមិនទាន់បរិបូណ៌ ដូចជាវិជ្ជាពេទ្យ វិជ្ជាកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្មជាដើម ដោយយកមកប្រើដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ របស់ដែលមិនត្រូវទទួល គឺវប្បធម៌អាសអាភាស ដូចជាទិវានៃសេចក្តីស្រឡាញ់ និងសាសនាដទៃ ព្រោះខ្មែរមានព្រះពុទ្ធសាសនាជាសាសនាបរិសុទ្ធ ជាមាគ៌ាធ្វើឲ្យអ្នកប្រតិបត្តិឆ្ពោះទៅកាន់ការរំលត់ទុក្ខ ដែលស្ថិតនៅក្នុងចិត្តគំនិតរបស់ខ្មែរ បានរលាយជាសាច់ជាឈាមរបស់ខ្លួនយ៉ាងរឹងមាំហើយ ។ សាកលភាវូបនីយកម្មប្រៀបដូចជាភ្លៀងធ្លាក់ វាលូតលាស់ទាំងសន្ទូង លូតលាស់ទាំងស្មៅ គេត្រូវកាត់ស្មៅចោលនិងថែទាំសន្ទូង ។ យ៉ាងណាមិញ ស្មៅប្រៀបដូចជាវប្បធម៌ដទៃ ត្រូវធ្វើច្បាប់ទប់ទល់ ឯសន្ទូងប្រៀបដូចវប្បធម៌ដ៏ផូរផង់របស់ខ្មែរ ដែលមានព្រះពុទ្ធសាសនាជាមូលដ្ឋាន ត្រូវថែទាំឲ្យគង់វង់ ។៚

❄ ❄

❄